Draft

# ជំពូក ១

## លក្ខណៈទូទៅ

## General

# ជំពូកទី ១

## លក្ខណៈទូទៅ (General)

### ១.១ សេចក្តីផ្តើម

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា គឺ ទឹក ផ្លូវ ភ្លើង និងធនធានមនុស្ស។ ដោយស្របតាមមាគាដឹកនាំដ៏ឆ្លាតវៃ នៃរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលបានដាក់ចេញនូវយុទ្ធសាស្ត្រទាំងបួននេះឡើង គឺដើម្បីស្តារកសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជា ដែលត្រូវខូចខាតដោយសារសង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំ ជាពិសេសដោយសាររបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ នោះការផលិតថាមពលអគ្គិសនីដោយប្រើចន្លទឹក គឺវារីអគ្គិសនីដែលជាសក្តានុពលដ៏សំខាន់នៃការរីកចំរើនសេដ្ឋកិច្ចរបស់កម្ពុជា ។

ពិតមែនតែគ្រប់វិស័យសុទ្ធតែមានសារៈសំខាន់ដូចៗ គ្នាសំរាប់បំរើការអភិវឌ្ឍ ប៉ុន្តែវារីអគ្គិសនីជាវិស័យអាទិភាពមួយ ដែលមានលក្ខណៈសមស្រប និងចាំបាច់បំផុតចំពោះស្ថានភាពបច្ចុប្បន្នប្រេងឥន្ធនៈឡើងថ្លៃ ហើយមិនការបំពុលខ្យល់ (ដោយ $CO_2$, $NO_x$, $SO_x$...etc ដែលធ្វើឱ្យកំដៅបរិយាកាស ផ្ទះកញ្ចក់ផែនដីឡើងទៀតផង)។ ដោយហេតុថាប្រទេសកម្ពុជាស្ថិតក្នុងតំបន់ត្រូពិច ដែលមានភ្លៀងធ្លាក់រយៈពេលប្រាំមួយខែក្នុងមួយឆ្នាំ រួមផ្សំនឹងសណ្ឋានដីសំបូរដោយជួរភ្នំ និងជ្រលងភ្នំនៅតាមបន្ទាត់ព្រំដែន និងតំបន់ឆ្នេរបង្កឱ្យមានសក្តានុពលសំរាប់អភិវឌ្ឍន៍វារីអគ្គិសនី ជាពិសេស គឺតំបន់កោះកុង-ជួរភ្នំក្រវាញ និងភ្នំសំកុស ខេត្តពោធិ៍សាត់នេះតែម្តង ។

ក្នុងគោលដៅស្រូបយកផលប្រយោជន៍ដ៏សំបូរបែប ដែលជាអំណោយផលធម្មជាតិរបស់កម្ពុជា និងក្នុងគោលដៅចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជា កាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនេះ ទើបសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៧ បានអនុម័តជាឯកច្ឆ័ន្ទ លើគំរោងអភិវឌ្ឍន៍វារីអគ្គិសនីអាតៃ និងគំរោងប្រព័ន្ធខ្សែបញ្ជូនតភ្ជាប់ភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង និងអនុស្សានីយទៅឱ្យ ក្រុមហ៊ុន C.H.D (Cambodia) Hydropower Development។ ក្រោយពីទទួលបានការអនុម័តនេះរួចមកក្រុមហ៊ុន C.H.D ត្រូវ បានអនុញ្ញាតឱ្យចុះហត្ថលេខា លើកិច្ចព្រមព្រៀងពាក់ព័ន្ធរួមមាន PPA, IA, LA ដើម្បីឱ្យគំរោងនេះ ចាប់ផ្តើមដំណើរការសាងសង់ បានឆាប់។ ផ្អែកទៅលើគោលការណ៍វិនិយោគក្រុមហ៊ុន C.H.D បានជ្រើសរើសយកក្រុមហ៊ុន China Yunnan Corporation for International Techno - Economic Cooperation ( CYC ) ជាអ្នកគ្រប់គ្រងផ្ទាល់លើផ្នែកវារីអគ្គិសនីអាតៃ និងក្រុមហ៊ុន Yunan Southeast - Asia Economy and Technology Investment Industrial Co., Ltd ជាអ្នកសាងសង់ទៅលើប្រព័ន្ធខ្សែចម្លង។ បន្ទាប់មកអគ្គនាយកក្រុមហ៊ុនអគ្គិសនីកម្ពុជា បានស្នើសុំការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជាជាមួយក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooperation(CYC) និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជាជាមួយក្រុមហ៊ុន Yunan Southeast-Asia Economy and Technology Investment Industrial Co., Ltd លិខិតនេះត្រូវបានយល់ព្រមពីអាជ្ញាធរអគ្គិសនី កម្ពុជានៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ និងទទួលការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ រាជរដ្ឋាភិបាល បានប្រទានសិទ្ធជូនឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងពីរដូចខាងក្រោម :

១- កិច្ចព្រមព្រៀងអនុវត្តន៍គំរោង និងកិច្ចព្រមព្រៀងជួល សំរាប់ការអភិវឌ្ឍអគ្គិសនីស្ទឹងអាតៃ ជាមួយក្រុមហ៊ុន

Draft

China Yunnan Corporation for International Techno - Economic Cooporation ( CYC )

២- កិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី គំរោងខ្សែបញ្ជូន ២៣០គីឡូវ៉ុល តភ្ជាប់ភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង ជាមួយក្រុមហ៊ុន Yunnan Southeast-Asia Economy and Technology Investment Industrial Co., Ltd ។

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ដដែលនេះ រាជរដ្ឋាភិបាល បានប្រទានសិទ្ធជូនឯកឧត្តម **គាត ឈន់** រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង IMPLEMENTATION AGREEMENT (IA) លើកិច្ចព្រមព្រៀង LEASE AGREEMENT (LA) និងលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ( FORM OF GOVERNMENT GUARANTEE OF PAYMENT ) ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅឱ្យក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooporation (CYC) សំរាប់គំរោងវារីអគ្គិសនី១២០ MW នៅស្ទឹងអាតៃ ខេត្តពោធិ៍សាត់ ។

ដើម្បីធ្វើឱ្យស្របតាមច្បាប់វិនិយោគនៅកម្ពុជានោះ ក្រុមហ៊ុនវិនិយោគត្រូវបង្កើតក្រុមហ៊ុនថ្មីមួយទៀតនៅកម្ពុជា គឺក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd. ដែលត្រូវបានបង្កើតឡើងដោយភាគហ៊ុននៃក្រុមហ៊ុនចំនួនបី មកពីប្រទេសចិន គឺ China Datang Corporation, China Yunnan Corporation for International Techno-Economic Cooporation (CYC), និង Yunnan Fortune Seecome Investment Industrial Co., Ltd. លើគំរោងវិនិយោគវារីអគ្គិសនីស្ទឹងអាតៃ។

ក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd. ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ក្នុងការសាងសង់វារីអគ្គិសនីនេះ គឺ មានសមាសភាពរបស់គំរោង ៣ សំខាន់ៗ (ចែកដោយក្រុមការងារ SAWAC ) ដូចជា: (១) អាងទី១ និងអាងទី២, (២) ហេដ្ឋារចនាសម្ព័ន្ធរបស់វារីអគ្គិសនី (មាន: ផ្លូវចូល, ទំនប់ទី១ និងទី២, អគារថាមពលទី១ និងទី២, ជំរុំកម្មករ, ឃ្លាំងនានា, រោងជាង, ការិយាល័យនៅការដ្ឋាន, រោងចក្រលាយបេតុង, កន្លែងយកថ្ម, កន្លែងកិនថ្ម, បំពង់រន្ធក្រោមដីទូនែល, និងកំពង់ចំណតទូក សាឡង់), និង(៣) ប្រពន្ធ័ខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ គ.វ៉ ពីអគារថមពលទី១ និងទី២។ ចំណែកឯអនុស្ថានីយ៍អូរសោម និងអនុស្ថានីយ៍ពោធិ៍សាត់ រួមទាំងខ្សែបញ្ជូនចរន្ត ២៣០ គ.វ៉ ជាការទទួលខុសត្រូវរបស់អគ្គិសនីកម្ពុជា ជាមួយនឹងក្រុមហ៊ុន Cambodia Power Grid Co., Ltd. (CPG) ។

គំរោងវារីអគ្គិសនីស្ទឹងអាតៃ អាចមានលទ្ធភាពផលិតថាមពលអគ្គិសនីបានប្រមាណ ១២០MW ហើយត្រូវការរយៈពេលសាងសង់០៤ឆ្នាំ (ចាប់ផ្តើមសាងសង់ពីខែវិច្ឆកា ឆ្នាំ២០០៩ និងបញ្ចប់នៅខែវិច្ឆកា ឆ្នាំ២០១៣) ។ គំរោងនេះ មានតំលៃវិនិយោគសរុប ២៤៦.៨៨៥.៦០០ (ពីររយសែសិបប្រាំមួយលាន ប្រាំបីរយប៉ែតសិបប្រាំពាន់ ប្រាំមួយរយដុល្លារអាមេរិក) ដុល្លារអាមេរិក ក្នុងនោះទុនវិនិយោគសំរាប់ប្រព័ន្ធខ្សែចម្លង១១៥ គ.វ ៣៧.០២៧.១០០ (សាមសិបប្រាំពីរលាន ម្ភៃប្រាំពីរពាន់ ប្រាំមួយរយ) ដុល្លារអាមេរិក។ ថវិកានេះមិនរាប់បញ្ចូលទុនវិនិយោគលើប្រពន្ធ័ខ្សែបញ្ជូនចរន្ត២៣០គ.វ និងអនុស្ថានីយ៍អូរសោម ចំនួន ៥៨.៤៤៩.៩០០ (ហាសិបប្រាំបីលានបួនរយសែសិបប្រាំបួនពាន់ ប្រាំបួនរយ) ដុល្លារអាមេរិកទេ។

ដោយមានការព្រមព្រៀងរវាងក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooporation (CYC) ជាមួយនឹង SAWAC Consultants for Development (ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍) ដើម្បីរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) លើគំរោងវារីអគ្គិសនីស្ទឹងអាតៃ ខេត្តពោធិ៍សាត់ របស់ក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooporation (CYC) ម្តងរួចមកហើយនៅឆ្នាំ២០០៨ ។ យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងបរិស្ថាន បានសម្រេចឱ្យម្ចាស់គំរោងនេះរៀបចំធ្វើ ជាការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ

Draft

(ESIA) ទៀត ។ បន្ទាប់មកក្រុមហ៊ុន CHD (Cambodia) បានទំនាក់ទំនង SAWAC ជាអ្នកអនុវត្ត រៀបចំរបាយការណ៍នេះទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។ឆ្លើយតបតាមតំរូវការនេះ SAWAC បានចាត់ក្រុមអ្នកជំនាញដែលទាក់ទងនឹងផ្នែកបរិស្ថាន អនុបណ្ឌិតសំណង់ស៊ីវិល ផ្នែកសំណង់ជលគតិ (MSc of Hydraulic Engineering Construction), វិស្វករបរិស្ថាន (Environmental Engineer), អ្នកជំនាញផ្នែកសេដ្ឋកិច្ច-សង្គម (Socio-Economist), វិស្វករជលផល (Fishery Engineer), វិស្វករព្រៃឈើ (Forest Engineer), អ្នកជំនាញផ្នែកពតិមាន ភូមិសាស្ត្រ (GIS Specialist), ក្រុមអ្នក សម្ភាសន៍ និងកំលាំងរក្សាសន្តិសុខ បានចុះទៅធ្វើការសិក្សាផ្ទាល់នៅក្នុងតំបន់គំរោង ដែលមានទំហំសរុបប្រមាណ ៥០៩៩ ហ.ត ដូចជាតំបន់អាងទី១ និងទី២ ៤២៣៧ ហ.ត, តំបន់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីប្រមាន ៨១៣ហ.ត និង តំបន់តាមគន្លងខ្សែបញ្ជូនចរន្ត ១១៥ គ.វ.ប្រមាណ ៤៩ហ.ត ចាប់តាំងពីថ្ងៃទី ០៥ ខែកក្កដា ដល់ ២០ ខែវិច្ឆកា ២០១១ (រួមទាំងរបាយការណ៍) ។ ចំពោះការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះមានរយៈពេល៥ខែ រួមទាំងការប្រមូលទិន្នន័យការសិក្សាស្រាវជ្រាវនៅការិយាល័យ ធ្វើការវិភាគទិន្នន័យ រៀបចំផែនទី ជំរើសគំនូរបច្ចេកទេស និងរៀបចំរបាយការណ៍នេះផងដែរ ។

នៅក្នុងឯកសារនេះបានបង្ហាញអំពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) របស់គំរោងវិនិយោគទុនលើវិស័យវារីអគ្គិសនីអាតៃខេត្តពោធិ៍សាត់របស់ក្រុមហ៊ុន CHD (Cambodia) ដែលបានកែតំរូវ និងបន្ថែមលម្អិតពីលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងរបស់គំរោងនេះ ខែកញ្ញា ឆ្នាំ២០០៩ ។ របាយ ការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) នេះរៀបចំទៅតាមប្រកាសស្តីពី គោលការណ៍ណែនាំទូទៅ ក្នុងការធ្វើ របាយការណ៍វាយតំលៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលេខៈ៣៧៦ ប្រក ប.ស្ថ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០០៩ ។ របាយការណ៍ ESIA នេះមាន ១១ ជំពូកគឺ (១) លក្ខណៈទូទៅ, (២) វិធីសាស្ត្រនៃការសិក្សា, (៣) ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ, (៤) ការពិពណ៌នាអំពីគំរោង, (៥) ការពិពណ៌នាបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង, (៦) ការចូលរួម និងការប្រឹក្សាយោបល់ពី សាធារណជន ក្នុងតំបន់គំរោង, (៧) ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និងវិធានការណ៍កាត់បន្ថយនៅក្នុងតំបន់គំរោងចំពោះហេដ្ឋារចនា សម្ព័ន្ធទំនប់វារីអគ្គិសនី, (៨) វិធានការណ៍កាត់បន្ថយនៅក្នុងតំបន់គំរោងចំពោះប្រព័ន្ធខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់១១៥គ.វ (៩) ផែនការគ្រប់គ្រងបរិស្ថាននៅក្នុង តំបន់គំរោង (១០) ការវិភាគសេដ្ឋកិច្ច និង តំលៃបរិស្ថាន និង (១១) សន្និដ្ឋាន និងអនុសាសន៍ ។

## ១.២ គោលបំណងនៃការសិក្សា និងវាយតំលៃ

ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នោះរាល់គំរោងអភិវឌ្ឍន៍ទាំងអស់ ត្រូវធ្វើការសិក្សាវាយតំលៃលើហេតុប៉ះពាល់បរិស្ថានជាមុនសិនរួចនឹងឈានចូលការអនុវត្តគំរោង និងយោងតាមច្បាប់កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ការសិក្សាសំរាប់កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់គំរោងនេះ គឺមានគោលបំណងសំខាន់ៗដូចតទៅៈ

- កែតំរូវ និងលម្អិតបន្ថែមលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង នាខែកញ្ញា ឆ្នាំ២០០៩
- សិក្សាលម្អិត និងស្វែងយល់ពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គំរោង ។

Draft

- សិក្សាលម្អិតសេដ្ឋកិច្ច-សង្គមនៃតំបន់គំរោងនឹងអភិវឌ្ឍន៍ និងសិក្សា-ធ្វើការវិភាគលើតំបន់ជុំវិញតំបន់គំរោង ដែលអាចទទួលរងនូវឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលពីគំរោងស្នើសុំអភិវឌ្ឍន៍នេះ រួមទាំងបណ្តុំនៃផលប៉ះពាល់រួមគ្នាជាមួយគំរោងដទៃទៀតផងដែរ ប្រសិនបើមាន ។
- កំណត់នូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថានវិជ្ជមាន និងអវិជ្ជមានដែលកើតឡើងពីសកម្មភាពរបស់គំរោងដោយប្រើប្រាស់តារាង Checklist របស់ធានាគារអភិវឌ្ឍន៍អាស៊ី និងរបស់ក្រសួងបរិស្ថានកម្ពុជា ។
- ដកស្រង់នូវអនុសាសន៍ និងទទួលយកនូវសំណូមពររបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង និងស្ថាប័នសាធារណៈដែលពាក់ព័ន្ធ នឹងគំរោងក្នុងនោះក៏មានអង្គការក្រៅរដ្ឋាភិបាលផងដែរ ដើម្បីរិះរកវិធានការយ៉ាងសុក្រឹតសំរាប់បន្ធូរបន្ថយផលប៉ះពាល់បរិស្ថានអវិជ្ជមានឱ្យដល់តិចបំផុតតាមការដែលអាចធ្វើទៅបាន។
- វាយតំលៃ និងប៉ាន់ប្រមាណហេតុប៉ះពាល់លើធនធានបរិស្ថានធម្មជាតិ និងសង្គមដែលបណ្តាលមកពីការរចនាប្លង់ ការសាងសង់ ប្រតិបត្តិ ថែទាំគំរោង និងបញ្ចប់ ឬបិទគំរោង ។
- ធ្វើការវិភាគសេដ្ឋកិច្ចនៃគំរោងដោយរួមទាំងការខូចខាតធនធានបរិស្ថានធម្មជាតិ ជីវសាស្រ្ត និងសង្គម ដើម្បីរកផលចំណេញរបស់គំរោង ។
- កំណត់នូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ជាពិសេសលើបរិស្ថានសង្គមឱ្យដល់កំរិតអប្បបរមា
- កំណត់នូវផែនការការពារបរិស្ថានរបស់គំរោងទៅថ្ងៃអនាគត ។
- ធ្វើការសន្និដ្ឋាន និងផ្តល់អនុសាស្រ្តសំខាន់ៗ ដែលធ្វើឱ្យម្ចាស់គំរោង និងស្ថាប័នទទួលខុសត្រូវអនុវត្តន៏គំរោងដោយមានភាពរលូន និងមានភាពនិរន្តភាព។

Draft